ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខៈ ១១៧០.........ប្រក.បទ.សហវ.ចមព

"...ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព"

# ប្រកាសអន្តរក្រសួង

## ស្តីពី

## អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍
- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តន៍ បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តន៍ បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្ដីពីវជ្ជទេយ្យចំណូល
- យោងកំណត់ហេតុអង្គប្រជុំអន្តរក្រសួង ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០៦។

## ស ម្រេ ច

**ប្រការ ១ :** ប្រកាសអន្តរក្រសួងនេះ មានគោលដៅគ្រប់គ្រង និងផ្ដល់អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ជូនផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬ នីតិបុគ្គល ធ្វើអាជីវកម្មបម្រើសេវា ទទួល ប្រមូល ដឹកជញ្ជូន និងចែកចាយនូវរាល់ សំបុត្រ កញ្ចប់តូច ឬ កញ្ចប់ធំ ដោយស្របច្បាប់បន្ថែមលើសេវាប្រៃសណីយ៍ដែលស្ថិតក្រោមអាជីវកម្មរបស់រដ្ឋ ដើម្បីជួយបំពេញសេវាប្រៃសណីយ៍ និងបម្រើតាមសំណូមពររបស់ប្រជាពលរដ្ឋ។

**ប្រការ ២ :** និយមន័យ

- អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ជាអាជ្ញាប័ណ្ណដែលក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ផ្ដល់ជូនផ្នែកឯកជន ជារូបវ័ន្តបុគ្គល ឬ នីតិបុគ្គល ធ្វើអាជីវកម្មបម្រើសេវា ទទួល ប្រមូល ដឹកជញ្ជូន និងចែកចាយនូវរាល់ សំបុត្រ កញ្ចប់តូច និងកញ្ចប់ធំ មានទម្ងន់អតិបរមា ៥០ គីឡូក្រាម និងនៅលើបញ្ញើនេះមានសរសេរអាសយដ្ឋានអ្នកផ្ញើ និងអ្នកទទួល ឬ អាសយដ្ឋានអ្នកទទួល ឬ លេខកូដសំគាល់។

- សេវាបញ្ញើឆាប់រហ័ស ជាសេវាកម្មទំនើបមួយ ដែលបានរៀបចំប្រព័ន្ធសេវាមានលក្ខណៈអន្តរជាតិ។ សេវានេះត្រូវមានកំណត់ពេលច្បាស់លាស់ ធានានូវសុវត្ថិភាព អាចជឿទុកចិត្តបាន ចាប់តាំងពី ទទួល ប្រមូល ដឹកជញ្ជូន និងចែកដល់ដៃអ្នកទទួល មានការកត់ត្រាតាមដានដោយប្រព័ន្ធព័ត៌មានវិទ្យាជាប្រចាំ ផ្លាស់ប្ដូរទៅតាមទិសដៅ និងមានបញ្ជាក់ពីការផ្ញើ និងទទួល។

- ការដឹកជញ្ជូនបញ្ញើឆាប់រហ័ស គឺជាការដឹកជញ្ជូនពីកន្លែងមួយ ទៅកន្លែងមួយទៀត តាមផ្លូវគោក ផ្លូវទឹក ឬ ផ្លូវអាកាស ដោយប្រើប្រាស់មធ្យោបាយមួយ ឬ ច្រើន ។

ប្រការ ៣ : គ្មានផ្នែកឯកជន ជារូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ អាចធ្វើអាជីវកម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដោយគ្មានអាជ្ញាប័ណ្ណ មានសុពលភាពដែលចេញដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ឡើយ ។

ប្រការ ៤ : ផ្នែកឯកជន ជារូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលអាចធ្វើអាជីវកម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិបាន ត្រូវមានលក្ខខណ្ឌដូចខាងក្រោម :

- មានសញ្ជាតិខ្មែរ ឬ បរទេស
- មានបទពិសោធន៍ខាងវិស័យប្រៃសណីយ៍ និង/ឬ ដឹកជញ្ជូនបញ្ញើឆាប់រហ័សអន្តរជាតិ
- បានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
- មានទីតាំងសមស្រប និងត្រូវមានឯកសារបញ្ជាក់ច្បាស់លាស់ ។

ប្រការ ៥ : ផ្នែកឯកជន ជារូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងចង់ធ្វើអាជីវម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណ នៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

ប្រការ ៦: ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចរបស់ក្រសួង តម្រូវឱ្យបំពេញបន្ថែមឯកសារចាំបាច់ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតពាក្យសុំ ក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលបានទទួលពាក្យសុំ ។

ប្រការ ៧: អ្នកកាន់អាជ្ញាប័ណ្ណមិនអាច ជួល លក់ ឬ បញ្ចាំ អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ទៅឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ផ្សេងទៀតបានឡើយ ។ ការបោះបង់ ឬ ការផ្ទេរ អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ទៅឱ្យ រូបវន្តបុគ្គល ឬ នីតិបុគ្គល ផ្សេងទៀត អាចធ្វើទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ប្រការ ៨: ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានសិទ្ធិក្នុងការកែសម្រួល ព្យួរ បដិសេធន៍ ឬ ដកហូត អាជ្ញាប័ណ្ណ ក្នុងករណីដូចខាងក្រោម :

ក- ការកែសម្រួលអាជ្ញាប័ណ្ណ ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណ បានជូនព័ត៌មានជាលាយលក្ខណ៍អក្សរ អំពីការ:

- ពង្រីកសាខាបន្ថែម
- ប្តូរទីតាំង
- លុបចោលសាខាមួយចំនួន ។

ខ- ការព្យួរអាជ្ញាប័ណ្ណ ក្នុងករណី អ្នកកាន់អាជ្ញាប័ណ្ណ :

- ធ្វើអាជីវកម្មខុសពីលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាប័ណ្ណ
- មិនបានអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចំនួនបីលើក ក្រោយពីបានជូនដំណឹងបីដង ក្នុងមួយដងៗមានរយៈពេល១០ថ្ងៃ នៃថ្ងៃធ្វើការ ។ អាជ្ញាប័ណ្ណ នេះនឹងត្រូវព្យួររហូតដល់អស់សុពលភាព បើសិនជាអ្នកកាន់អាជ្ញាប័ណ្ណមិនចូលមកដោះស្រាយ ។
- ត្រូវបានស្ថាប័នមានសមត្ថកិច្ចស្នើសុំឱ្យព្យួរ ដោយមូលហេតុមានការរំលោភលើលិខិតបទដ្ឋានច្បាប់ ជាធរមាន ។

គ- ការបដិសេធន៍ ឬ ដកហូតអាជ្ញាប័ណ្ណក្នុងករណី :

- អាជ្ញាប័ណ្ណអស់សុពលភាពហើយពុំបានស្នើសុំបន្ត
- អាជ្ញាប័ណ្ណត្រូវបានព្យួរ ២ដង ហើយពុំរាងចាល
- អ្នកកាន់អាជ្ញាប័ណ្ណបាន ជួល លក់ ឬ បញ្ចាំ អាជ្ញាប័ណ្ណរបស់ខ្លួនទៅឱ្យ រូបវ័ន្តបុគ្គល ឬ នីតិបុគ្គលផ្សេងទៀត ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។
- អ្នកកាន់អាជ្ញាប័ណ្ណពុំបានធ្វើសកម្មភាពអាជីវកម្មរយៈពេល៦ខែ ក្រោយពីទទួលបានអាជ្ញាប័ណ្ណ ។

**ប្រការ ៩:** ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវជូនដំណឹងដល់អ្នកកាន់អាជ្ញាប័ណ្ណ ជាលាយលក្ខណ៍អក្សរ និងចុះផ្សាយតាមបណ្តាញព័ត៌មាន នូវសេចក្តីសម្រេចរបស់ក្រសួង ចំពោះការបដិសេធន៍ ឬ ដកហូតមកវិញនូវអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ។ អ្នកកាន់អាជ្ញាប័ណ្ណអាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរមកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងរយៈពេល ២៥ថ្ងៃ ចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងតាមបញ្ញើអនុសិដ្ឋរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ ១០:** អាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេលតិចបំផុត១ឆ្នាំ និងច្រើនបំផុត១០ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ ក្នុងករណីអាជ្ញាប័ណ្ណអស់សុពលភាព អ្នកកាន់អាជ្ញាប័ណ្ណអាចដាក់ពាក្យសុំបន្តឱ្យបានមុន៣០ថ្ងៃ ។

**ប្រការ ១១:** តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ គណនាតាមសុពលភាពនៃអាជ្ញាប័ណ្ណនីមួយៗដូចតទៅ:

ក- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ១ឆ្នាំ ត្រូវបានកំណត់ ៣០.៧០០.០០០រៀល ។

ខ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ២ឆ្នាំ ត្រូវបានកំណត់ ៥៩.២០០.០០០រៀល ។

គ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៣ឆ្នាំ ត្រូវបានកំណត់ ៨៥.៦០០.០០០រៀល ។

យ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៤ឆ្នាំ ត្រូវបានកំណត់ ១០៩.៩០០.០០០រៀល ។

ង- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៥ឆ្នាំ ត្រូវបានកំណត់ ១៣២.៦០០.០០០រៀល ។

ច- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៦ឆ្នាំ ត្រូវបានកំណត់ ១៥៣.៥០០.០០០រៀល ។

ឆ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៧ឆ្នាំ ត្រូវបានកំណត់ ១៧២.៩០០.០០០រៀល ។

ជ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៨ឆ្នាំ ត្រូវបានកំណត់ ១៩០.៨០០.០០០រៀល ។

ឈ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ៩ឆ្នាំ ត្រូវបានកំណត់ ២០៧.៥០០.០០០រៀល ។

ញ- តម្លៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ មានសុពលភាពរយៈពេល ១០ឆ្នាំ ត្រូវបានកំណត់ ២២២.៨០០.០០០រៀល ។

តម្លៃអាជ្ញាប័ណ្ណទាំង១០ប្រភេទខាងលើនេះត្រូវបង់ប្រាក់កក់ចំនួន ២.០០០.០០០រៀល នៅពេល ដាក់ពាក្យសុំដំបូង និងបង់បង្គ្រប់នៅពេលទទួលបានគោលការណ៍អនុញ្ញាត ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ក្នុងករណីស្នើសុំអាជ្ញាប័ណ្ណពុំទទួលបានការអនុញ្ញាត ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រាក់កក់ដំបូងចំនួន ២.០០០.០០០រៀល ត្រូវប្រគល់ជូនអ្នកស្នើសុំវិញ ។

ក្នុងករណីអ្នកដាក់ពាក្យ បានបោះបង់ចោលការស្នើសុំអាជ្ញាប័ណ្ណ ក្រោយពេលគោលការណ៍ត្រូវបានអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រាក់កក់ចំនួន ២.០០០.០០០រៀល ត្រូវបង្វែរចូលថវិកាជាតិ ។

ប្រការ ១២: អ្នកកាន់អាជ្ញាប័ណ្ណចង់ពង្រីកសាខាបន្ថែម ឬ ប្តូរទីតាំង ឬ សុំលុបចោលសាខាមួយចំនួនដែលមានចែងក្នុងអាជ្ញាប័ណ្ណ ត្រូវផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរជាមុន ជូនមកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

ប្រការ ១៣ : អ្នកកាន់អាជ្ញាប័ណ្ណអាចបម្រើសេវាបញ្ញើប្រៃសណីយ៍តាមយន្តហោះ ដែលមានទម្ងន់ក្រោម៥០០ក្រាមបាន ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណនោះគិតតម្លៃសេវា លើសពី៥ដង នៃតម្លៃសេវាមូលដ្ឋានរបស់រដ្ឋ ។

ប្រការ ១៤: អ្នកកាន់អាជ្ញាប័ណ្ណ អាចធ្វើអាជីវកម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិគ្រប់ប្រភេទ លើកលែងតែវត្ថុដែលត្រូវហាមឃាត់ ដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ។

ប្រការ ១៥: អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់របាយការណ៍បរិមាណផលិតផលដែលបានធ្វើអាជីវកម្ម ជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រៀងរាល់ត្រីមាសឱ្យបានទៀងទាត់ ។ របាយការណ៍នេះត្រូវបានរក្សាការសំងាត់ ។

ប្រការ ១៦: អ្នកកាន់អាជ្ញាប័ណ្ណត្រូវទទួលខុសត្រូវ និងសងចំពោះអ្នកផ្ញើ ឬ អ្នកទទួល ក្នុងករណីមានការបាត់បង់ ឬ ខូចខាតនូវរាល់បញ្ញើឆាប់រហ័សអន្តរជាតិ លើកលែងបញ្ញើត្រូវបានបាត់បង់ ឬ ខូចខាត ដោយករណីប្រធានស័ក្តិ ឬ បញ្ញើដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌត្រូវបានរឹបអូស ។ សំណងនេះត្រូវសងរហូតដល់តម្លៃអតិបរមាមួយដែលកំណត់ដោយក្រុមហ៊ុន ។

ប្រការ ១៧: អ្នកផ្ញើ ឬ អ្នកទទួល មានសិទ្ធិប្តឹងតវ៉ាអំពីបញ្ញើឆាប់រហ័សអន្តរជាតិ ដែលបានបាត់បង់ ឬ ខូចខាតចំពោះអ្នកកាន់អាជ្ញាប័ណ្ណដែលខ្លួនបានផ្ញើ ឬ ទទួលក្នុងអំឡុងពេល ០៦ខែ គិតចាប់ពីថ្ងៃផ្ញើ ឬថ្ងៃទទួលបញ្ញើ ។

ប្រការ ១៨: នាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័ត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានភារកិច្ចគ្រប់គ្រងអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ និងតាមដាននូវរាល់សកម្មភាពរបស់ក្រុមហ៊ុនធ្វើអាជីវកម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ឱ្យអនុវត្តត្រឹមត្រូវតាមខ្លឹមសារនៃអាជ្ញាប័ណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដែលបានផ្តល់ជូន និងតាមច្បាប់ លិខិតបទដ្ឋានដែលមាន ជាធរមាន ។

ប្រការ ១៩: នាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានភារកិច្ចត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនធ្វើអាជីវកម្មបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ ដើម្បីកសាងសំណុំឯកសារ នៅពេលមានវិវាទ ឬ បណ្តឹងតវ៉ាផ្សេងៗ ។

ប្រការ ២០: - អ្នកកាន់អាជ្ញាប័ណ្ណទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងប្រការ ១៤ នៃប្រកាសអន្តរក្រសួងនេះ ត្រូវទទួលពិន័យ និង/ឬ ផ្តន្ទាទោសតាម មាត្រា៤៦ នៃច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ។

- ត្រូវពិន័យជាប្រាក់ពី១.០០០.០០០រៀល ដល់ ១០.០០០.០០០រៀល អ្នកកាន់អាជ្ញាប័ណ្ណមិនគោរពតាមបញ្ញត្តិ ដូចមានចែងក្នុង ប្រការ១២ នៃប្រកាសអន្តរក្រសួងនេះ ។ ករណីមិនរាងចាលត្រូវដកហូតអាជ្ញាប័ណ្ណ ដោយប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

- ត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០រៀល ដល់ ១០.០០០.០០០រៀល ចំពោះជនណាដែលធ្វើអាជីវកម្មបម្រើសេវាទទួល ប្រមូល ដឹកជញ្ជូន និងចែកចាយបញ្ញើឆាប់រហ័សអន្តរជាតិ ដោយគ្មានអាជ្ញាប័ណ្ណដូចមានចែងក្នុងប្រការ៣ នៃប្រកាសអន្តរក្រសួងនេះ ហើយត្រូវបញ្ឈប់អាជីវកម្មខុសច្បាប់នេះជាបន្ទាន់ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។ ករណីមិនរាងចាលត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

- អ្នកកាន់អាជ្ញាប័ណ្ណ មិនគោរពតាមបញ្ញត្តិដូចមានចែងក្នុងប្រការ៧ នៃប្រកាសអន្តរក្រសួងនេះត្រូវពិន័យជាប្រាក់ ពី ៥.០០០.០០០រៀល ដល់ ២០.០០០.០០០រៀល ហើយត្រូវដកហូតអាជ្ញាប័ណ្ណ ។

**ប្រការ ២១:** រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនៃប្រកាសអន្តរក្រសួងនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២២:** អគ្គនាយកដ្ឋាន នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសអន្តរក្រសួងនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

សូរ-ឃុន

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ...គ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គ្រប់សាលាខេត្តក្រុង

"ដើម្បីជូនជ្រាប"

- ដូចប្រការ ២២

"ដើម្បីអនុវត្ត"

- ឯកសារ- កាលប្បវត្តិ